# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

www.pheakdeylaw.com

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ពីខ្ទង់ចំណាយមិនទាន់បែងចែក ជូនក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ,ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះ :

ឯកតា : លានរៀល

| ជំពូក | បរិយាយ | ស្ថានភាពឥណទានដើមឆ្នាំ | ចលនាឥណទាន កើន | ចលនាឥណទាន ថយ | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|---|
| | **ការផ្ទេរចេញ** | | | **91.000** | |
| | **៩៩.ចំណាយមិនទាន់បែងចែក** | | | **91.000** | |
| 12 | ប្រាក់ឧបត្ថម្ភ សំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល | 51.000 | - | 31.000 | 20.000 |
| 20 | ការប្រាក់លើការខ្ចីបុល រយៈពេលវែង មធ្យម និង ខ្លី | 25.000 | - | 25.000 | - |
| 40 | ចំណាយផ្សេងៗ | 110.000 | - | 10.000 | 100.000 |
| 53 | ការទូទាត់បំណុល | 25.000 | - | 25.000 | - |
| | **ការផ្ទេរចូល** | | **91.000** | | |
| | **០៩.ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ** | | **5.000** | | |
| 11 | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | 31.150 | 5.000 | - | 36.150 |
| | **១០.ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** | | **81.000** | | |
| 12 | ប្រាក់ឧបត្ថម្ភ សំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល | - | 31.000 | - | 31.000 |
| 20 | ការប្រាក់លើការខ្ចីបុល រយៈពេលវែង មធ្យម និង ខ្លី | - | 25.000 | - | 25.000 |
| 53 | ការរំលស់បំណុល | - | 25.000 | - | 25.000 |
| | **៣០.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** | | **5.000** | | |
| 11 | ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច | 1.670 | 5.000 | - | 6.670 |

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

www.pheakdeylaw.com

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០២ តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

www.pheakdeylaw.com